ក

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2003

## មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម


១៦-៨-២០០១ - ព្រះរាជក្រម នស/រកម/០៨០១/១៣ស្តីពីការអនុម័តយល់ ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងមូលនិធិអូប៉ិចសំរាប់ការអភិវឌ្ឍន៍អន្តរជាតិដើម្បីការលើកទឹកចិត្ត និងការការពារវិនិយោគ ២២៤១


### ២. ព្រះរាជក្រឹត្យ


១៦-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៧៥ ស្តីពីការបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **តាវ សេងហួរ** អនុប្រធានក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ២២៤៣

១៨-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៧៦ ស្តីពីការតែងតាំង អភិបាលខេត្ត-ក្រុងចំនួន ០៤ រូប ២២៤៤

១៨-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៧៧ ស្តីពីការផ្លាស់ប្តូរនិងផ្ទេរភារកិច្ចអភិបាលខេត្ត-ក្រុងចំនួន ០៤ រូបឱ្យមកបំរើការងារនៅទីស្តីការក្រសួង-ស្ថាប័នដើមវិញ ២២៤៥

១៩-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៧៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ ហៅកាត់ " គ.ជ.ប.អ " ២២៤៦

២២-៨-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៨០ ស្តីពីការបំពាក់គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាថ្នាក់ **អស្សឫទ្ធិ** ជូន ឯកឧត្តម **ឈន អៀម** ២២៥១


## II- រាជរដ្ឋាភិបាល

### ១. អនុក្រឹត្យ


១៧-៨-២០០១ - អនុក្រឹត្យលេខ ៨១ អនក្រ បក ស្តីពីការកាត់ផ្ទៃដីក្របាមពីដែនព្រៃសម្បទានសំរាប់ចំការកៅស៊ូ ២២៥២

២៣-៨-២០០១ - អនុក្រឹត្យលេខ ៨២ អនក្រ បក ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការ ដ្ឋាននៃគណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ ២២៥៤

១៦-៨-២០០១ - អនុក្រឹត្យលេខ ៣៧២ អនក្រ តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២២៥៩

១៦-៨-២០០១ - អនុក្រឹត្យលេខ ៣៧៣ អនក្រ តត ស្តីពីការតែងតាំងអភិបាលរងខេត្ត ២២៦១

១៦-៨-២០០១ - អនុក្រឹត្យលេខ ៣៧៤ អនក្រ តត ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌរដ្ឋ ២២៦២

១៦-៨-២០០១ - អនុក្រឹត្យលេខ ៣៧៥ អនក្រ តត ស្តីពីការតែងតាំងអភិបាលរងខេត្ត-ក្រុង ២២៦៣

១៦-៨-២០០១ - អនុក្រឹត្យលេខ ៣៧៦ អនក្រ តត ស្តីពីការផ្លាស់ប្តូរនិងផ្ទេរភារកិច្ចអភិបាលរងខេត្ត ២២៦៤

១៦-៨-២០០១ - អនុក្រឹត្យលេខ ៣៧៧ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៦៥

១៧-៨-២០០១ - អនុក្រឹត្យលេខ ៣៧៨ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២៦៦

១៧-៨-២០០១ - អនុក្រឹត្យលេខ ៣៧៩ អនក្រ តត ស្តីពីការតែងតាំង លោក **អន ប៊ុណ្ណារឿន** ជាប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការវិជ្ជាជីវៈសារពត៌មាន នៃក្រសួងពត៌មាន ២២៦៨

២០-៨-២០០១ - អនុក្រឹត្យលេខ ៣៨០ អនក្រ តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២២៦៩

២០-៨-២០០១ - អនុក្រឹត្យលេខ ៣៨១ អនក្រ តត ស្តីពីការជូនមេដាយការងារ ២២៧១

២០-៨-២០០១ - អនុក្រឹត្យលេខ ៣៨២ អនក្រ តត ស្តីពីការជូនមេដាយការងារ ២២៧៣

២០-៨-២០០១ - អនុក្រឹត្យលេខ ៣៨៣ អនក្រ តត ស្តីពីការជូនមេដាយការងារ

២០-៨-២០០១ - អនុក្រឹត្យលេខ ៣៨៤ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៧

២០-៨-២០០១ - អនុក្រឹត្យលេខ ៣៨៥ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៧៨

២១-៨-២០០១ - អនុក្រឹត្យលេខ ៣៨៦ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២៧៩

២១-៨-២០០១ - អនុក្រឹត្យលេខ ៣៨៧ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២៨០

២១-៨-២០០១ - អនុក្រឹត្យលេខ ៣៨៨ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២៨១

២៣-៨-២០០១ - អនុក្រឹត្យលេខ ៣៨៩ អនក្រ តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២២៨២

២៣-៨-២០០១ - អនុក្រឹត្យលេខ ៣៩០ អនក្រ តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២២៨៣

# III- ការងាររបណ្ដាក្រសួង

## ១_ ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

២២-៨-២០០១ - សេចក្ដីសំរេចលេខ ៣៧៤ សសរ .កសក ស្ដីពីការតែងតាំងគណៈ កម្មការរៀបចំពិធីដាំកប្បាសនៅស្រុកមេមត់ ខេត្តកំពង់ចាម ២២៨៤

## ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១៦-៨-២០០១ -ប្រកាសលេខ ៩៤១ ឧរថ.ឧតសប្រក ស្ដីពីការអនុញ្ញាតឱ្យលោក **ជូ សុចិត្រ** អាសយដ្ឋានក្រុមទី ២៦ មណ្ឌល២ សង្កាត់លេខ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហានុបន្តដំណើរការសិប្បកម្មផលិតទឹកសំណែក និងទឹកផ្លែឈើ " រូបទន្សាយពីរ នៅក្នុងទីតាំងខាងលើ ២២៨៦

១៦-៨-២០០១ - ប្រកាសលេខ ៩៤២ ឧរថ.ឧតសប្រក ស្ដីពីការអនុញ្ញាតឱ្យអ្នកស្រី **ហេង ហៀក** ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ន ភូមិល្វាសរកណ្ដាល ឃុំល្វាសរ ស្រុកល្វាឯម ខេត្តកណ្ដាលបើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិកោះកែវលើ ឃុំកោះកែវ ស្រុកល្វាឯម ខេត្តកណ្ដាល

១៦-៨-២០០១ - ប្រកាសលេខ៩៤៣ ឧរថ.ឧតសប្រក ស្ដីពីការអនុញ្ញាតឱ្យលោក **ឈាង គឹមឈួន** ជនជាតិខ្មែរ មានទីលំនៅផ្ទះលេខ ៤ CEo ផ្លូវលេខ ១៩០សង្កាត់បឹងព្រលិត ខ័ណ្ឌ ៧មករា រាជធានីភ្នំពេញបន្តដំណើរការសិប្បកម្មកាត់កញ្ចក់ឆ្លុះមុខ នៅក្នុងទីតាំងដូចខាងលើ ២២៨៨

១៦-៨-២០០១ - ប្រកាសលេខ៩៤៤ ឧរថ.ឧតសប្រក ស្ដីពីការអនុញ្ញាតឱ្យអ្នកស្រី **គុណា សុធា** ជនជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ១៣៨ ផ្លូវលេខ ១៨៦ក្រុមទី២៥ សង្កាត់ទឹកល្អក់៣ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញបន្តដំណើរការសិប្បកម្មតូច ផលិត ទឹកបរិសុទ្ធ " ត្បូងពេជ្រ" នៅក្នុងទីតាំងដូចខាងលើ ២២៨៩

១៦-៨-២០០១ - ប្រកាសលេខ ៩៤៥ ឧរថ.ឧតសប្រក ស្ដីពីការអនុញ្ញាតឱ្យអ្នកស្រី **សោម គីណា** ជនជាតិខ្មែរ អាសយដ្ឋានក្រុមទី ១៣ ភូមិទី ៣ សង្កាត់លេខ៤ ខ័ណ្ឌមិត្តភាពក្រុង ព្រះសីហានុ បន្តដំណើរការឡផលិតនំប៉័ង" អនាម័យ" នៅក្នុងទីតាំងក្រុមទី ៧ មណ្ឌល៤ សង្កាត់លេខ៤ ខ័ណ្ឌមិត្តភាពក្រុងព្រះសីហានុ ២២៩០

១៧-៨-២០០១ - ប្រកាសលេខ៩៥៦ ឧរថ.ឧតសប្រក ស្ដីពីការអនុញ្ញាតឱ្យលោក **ណាត់ ធី** ជនជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ២២ Eo ភូមិតាង៉ោ សង្កាត់ច្បារអំពៅទី១

| | | |
|---|---|---|
| | ខណ្ឌ មានជ័យ រាជធានីភ្នំពេញបន្តដំណើរការផលិតនំប៉ុងផ្អែម " Q B " នៅក្នុងទីតាំង ផ្ទះលេខ ១៣២អា ផ្លូវលេខ ១១០ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ | ២២៩១ |
| ១៧-៨-២០០១ | - ប្រកាសលេខ៥៥៧ ឧរថ.ឧតសប្រក ស្តីពីការអនុញ្ញាតឱ្យលោក **យ៉េម ធា** ជនជាតិខ្មែរ អាសយដ្ឋានភូមិធម្មយុត្តិ ឃុំប្អេរ ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ៨០ សេះ នៅក្នុងទីតាំងដូចខាងលើ | ២២៩២ |
| ១៧-៨-២០០១ | - ប្រកាសលេខ៥៥៨ ឧរថ.ឧតសប្រក ស្តីពីការអនុញ្ញាតឱ្យលោក **ហេង ជួ** ជនជាតិខ្មែរ អាសយដ្ឋានផ្ទះលេខ ៩៣ Eo ផ្លូវលេខ ១៤៨ក្រុមទី២៨សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញបន្តដំណើរការរោងជាងក្រឡឹងដែក នៅក្នុងទីតាំងដូចខាងលើ | ២២៩៣ |
| ១៧-៨-២០០១ | - ប្រកាសលេខ៥៥៩ ឧរថ.ឧតសប្រក ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **តាំង គាច** ជនជាតិខ្មែរ អាសយដ្ឋានភូមិចំការតាម៉ៅ ឃុំស្រែថ្មី ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កម្លាំង ២៤ សេះនៅ ក្នុងទីតាំងដូចខាងលើ | ២២៩៤ |

# ព្រះរាជក្រម

នស/រកម/០៨០១/១៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពី សម្តេចនាយករដ្ឋមន្ត្រី និងពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង មូលនិធិ អូប៉ិច សម្រាប់ការអភិវឌ្ឍអន្តរជាតិ ដើម្បីការលើកទឹកចិត្ត និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និង គតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គ លើកទី ៥ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៈ/.

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជានិងមូលនិធិអូប៉ិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដើម្បីការលើកទឹកចិត្តនិងការការពារវិនិយោគ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងមូលនិធិអូប៉ិចសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដើម្បីការលើកទឹកចិត្តនិងការការពារវិនិយោគដែលត្រូវបានចុះហត្ថលេខានៅទីក្រុងវីយ៉ែន ប្រទេសអូទ្រីស នាថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០០១

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ១៩៤ ចល

[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧៥

យើង

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **តាន សេងហួរ** អនុប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និង ជនបទ ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ លើការងារស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និង ជនបទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ១៨៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១

នស/រកត/០៨០១/២៧៦

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំងអភិបាល ខេត្ត-ក្រុង ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ស៊ឹម សុន ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអភិបាលក្រុងកែប
២- ឯកឧត្តម សាយ ហាក់ ជាអភិបាលក្រុងព្រះសីហនុ
៣- ឯកឧត្តម ពុត ចន្ទរិទ្ធ ជាអភិបាលខេត្តកំពត
៤- ឯកឧត្តម ខ្សៃ ទីរៈ ជាអភិបាលខេត្តឧត្តរមានជ័យ

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ១៤៥ ច.ល

ភ្នំពេញ,ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០១

ជូនអ្នកចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ៨ ឆ្នាំ ២០០១
អគ្គលេខាធិការរាជរដ្ឋាភិបាល
សារ៉ឺ សាន

នស/រកត/០៨០១/២៧៧

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១** : ផ្លាស់ប្តូរ និងផ្ទេរភារកិច្ចអភិបាលខេត្ត-ក្រុង ចំនួន ០៤ រូប អោយមកបំរើការងារ នៅទីស្តីការក្រសួងស្ថាប័នដើមវិញ ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម ទាវ ឧត្តារ៉ា ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអភិបាលក្រុងកែប

២- ឯកឧត្តម អ៊ុត ជេតតូឡា អភិបាលក្រុងព្រះសីហនុ

៣- ឯកឧត្តម លី ស្ទូ អភិបាលខេត្តកំពត

៤- ឯកឧត្តម ឈុង សារិន អភិបាលខេត្តឧត្តរមានជ័យ

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

ព្រះហស្ថលេខា

នរោត្តម សីហនុ

ព្រះ ... ច.ល

ភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០១

ដើម្បីចំលងចែកជូន

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស. ... តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៧៩

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សំណើនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១** : បង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ ហៅកាត់ **គ.ជ.ប.អ** ជាជំនួយក្នុងការអនុវត្តន៍ និងតាមដានគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាក់ទងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ឱ្យមានប្រសិទ្ធភាព ។ល។

មាត្រា ២ : គ.ជ.ប.អ មានគោលដៅដូចតទៅៈ

- លើកកំពស់សមត្ថភាពរបស់ប្រជាជន ដើម្បីការអភិវឌ្ឍន៍ ដោយចីរភាព
- ជំរុញឱ្យមានការយល់ដឹងឱ្យបានទូលំទូលាយ ពីបញ្ហាប្រជាជនទាក់ទិននឹងបរិស្ថាន សុខភាព ការអប់រំ ។ល។
- ផ្តល់លទ្ធភាពពេញលេញដល់ប្រជាជនក្នុងការចូលរួម ដើម្បីកំណត់អាទិភាព និងគោលដៅនានា សំរាប់ការអភិវឌ្ឍន៍
- ជំរុញ និងសំរបសំរួល ក្នុងការបង្កើតផែនការជាតិឱ្យស៊ីជំរៅជាងមុន ពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ នៅក្នុងបណ្តាតំរេងរបស់ក្រសួងពាក់ព័ន្ធ ។

## ជំពូកទី ២

## សមាសភាព បេសកកម្ម និង ភារកិច្ច

មាត្រា ៣ : គណៈកម្មាធិការជាតិដើម្បីប្រជាជននិងការអភិវឌ្ឍន៍ " គ.ជ.ប.អ " មានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១- | សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬតំណាង | សមាជិក |
| ៤- | រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ៥- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬតំណាង | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬតំណាង | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ឬតំណាង | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬតំណាង | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ឬតំណាង | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឬតំណាង | សមាជិក |
| ១៣- | សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬតំណាង | សមាជិក ៕. |

**មាត្រា ៤** : **គ.ជ.ប.អ** មានបេសកកម្មដូចតទៅ:

- ធានាកិច្ចសហការ សំរបសំរួល ដ៏សមស្របក្នុងការអនុវត្តន៍ គោលនយោបាយ និងកម្មវិធី ដែលទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ ។
- ត្រួតពិនិត្យតាមដាន និងវាយតំលៃពីគោលនយោបាយទាំងឡាយនិងកម្មវិធីដែលទាក់ទង នឹង ជីវភាពរស់នៅ ការអភិវឌ្ឍន៍ ការការពារ និងលើកកំពស់ សុខមាលភាព ការចូលរួម ចំណែករបស់ប្រជាជន ។

**មាត្រា ៥** : ដើម្បីសំរេចបាននូវគោលដៅ និងបេសកកម្មខាងលើនេះ **គ.ជ.ប.អ** មានភារកិច្ចដូចតទៅ:

- ស្រាវជ្រាវ និងផ្សព្វផ្សាយជូនពត៌មាន ស្តីពីសេចក្តីត្រូវការ និង បញ្ហាទាំងឡាយដែល ពាក់ព័ន្ធនឹងប្រជាជន ជូនទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គភាពនានា ។
- ជួយរាជរដ្ឋាភិបាលក្នុងការតាមដាននិងធ្វើរបាយការណ៍លើបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹង បញ្ហាប្រជាជននិងការអភិវឌ្ឍន៍ ។
- សំរបសំរួល និងសហប្រតិបត្តិការ រវាងអន្តរក្រសួងក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹង បញ្ហាប្រជាជន និងការអភិវឌ្ឍន៍ដើម្បីធានានូវភាពរលូនក្នុងការអនុវត្តន៍គោលនយោបាយ របស់ រាជរដ្ឋាភិបាលឱ្យមានប្រសិទ្ធភាព ។
- សំរបសំរួលជាមួយគណៈកម្មការនៃរដ្ឋសភាក្នុងក្របខ័ណ្ឌជាតិ ដែលពាក់ព័ន្ធនឹងច្បាប់ប្រជាជន ដើម្បីជាជំនួយក្នុងការសំរេចគោលដៅ កម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- សំរបសំរួល និងសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ ប្រទេសផ្តល់ជំនួយ សង្គមស៊ីវិល ស្ថាប័នឯកជន ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ដើម្បីធានា ភាពជាដៃគូរក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- ទំនាក់ទំនង និងផ្លាស់ប្តូរបទពិសោធន៍ ទស្សនៈជាវិជ្ជមាន និងកម្មវិធីថ្មីៗនៅក្នុងតំបន់ ក៏ដូចជាក្រៅតំបន់ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ ។
- សំរបសំរួល និងដឹកនាំសិក្ខាសាលា សន្និសីទជាតិ និងអន្តរជាតិដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ ។
- សំរបសំរួល និងដឹកនាំសិក្ខាសាលា វគ្គបណ្តុះបណ្តាលដល់មន្ត្រីរាជការ តាមក្រសួង តាមតំបន់ និង ខេត្ត-ក្រុង ដើម្បីបង្កើនចំណេះដឹង និងស្វែងយល់អំពីទំនាក់ទំនងរវាងបញ្ហាប្រជាជន និង ការអភិវឌ្ឍន៍ ។ល។

## ជំពូកទី ៣

## រចនាសម្ព័ន្ធ

**មាត្រា ៦** : **គ.ជ.ប.អ** មានរចនាសម្ព័ន្ធចាត់តាំង ដើម្បីដំណើរការដូចខាងក្រោម :

- មានអគ្គលេខាធិការដ្ឋានមួយ និងមានការិយាល័យមួយចំនួនសំរាប់បំរើការងារ ដែលមានទីតាំងនៅ ទីស្តីការគណៈរដ្ឋមន្ត្រី ឬ អាចប្តូរទៅកន្លែងដទៃទៀតទៅតាមការចាំបាច់ ។
- អាចបង្កើតគណៈកម្មការជំនាញ និងគណៈកម្មការតំបន់ ដើម្បីធ្វើការមួយរយៈ តាមការកំណត់
- **គ.ជ.ប.អ** អាចមានទីប្រឹក្សាមួយចំនួនដែលមានសមត្ថភាពជំនាញដើម្បីជួយការងារ ។

**មាត្រា ៧** : ប្រធាន ឬអនុប្រធាន មានសិទ្ធិតែងតាំងអ្នកមានជំនាញ - ឥស្សរជន ឬ មន្ត្រីជាន់ខ្ពស់ដែលមានបទពិសោធន៍ និងសមត្ថភាព ដើម្បីសំរួលដំណើរការការងាររបស់គណៈកម្មាធិការជាតិនេះ ។

**មាត្រា ៨** : ប្រធាន ឬអនុប្រធាន គ.ជ.ប.អ អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានគុណសម្បត្តិគ្រប់គ្រាន់មកចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ។

**មាត្រា ៩** : **គ.ជ.ប.អ**មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងដំណើរការការងាររបស់ខ្លួន ។

**មាត្រា ១០** : តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា តំណាងវិជ្ជាស្ថានស្រាវជ្រាវពាក់ព័ន្ធនឹងប្រជាជន និងការអភិវឌ្ឍន៍ទាំងក្នុង និងក្រៅប្រទេស អង្គការជំនួយទ្វេភាគី អាចចុះជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់ **គ.ជ.ប.អ** ។

**មាត្រា ១១** : អគ្គលេខាធិការដ្ឋាននៃ **គ.ជ.ប.អ** ជាអង្គភាពប្រតិបត្តិ ដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយនាយកប្រតិបត្តិមួយរូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងនាយកប្រតិបត្តិរងពីររូប ។

**មាត្រា ១២** : ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិនេះនឹងត្រូវកំនត់ដោយអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ១៣** : បុគ្គលិក ឬ អ្នកជំនាញបំរើការងារនៅ **គ.ជ.ប.អ** ត្រូវជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។ ក្នុងករណីចាំបាច់ **គ.ជ.ប.អ** អាចជួលអ្នកជំនាញ ឬបុគ្គលិកក្រៅក្របខ័ណ្ឌបាន ។

## ជំពូកទី ៤

## ប្រភពធនធាន

**មាត្រា ១៤** : **គ.ជ.ប.អ** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិក្នុងកញ្ចប់ថវិកានៃទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់បញ្ហាប្រជាជន និងការអភិវឌ្ឍន៍ និងដោយជំនួយពីក្នុងប្រទេស និងក្រៅប្រទេស ។ល។

### ជំពូកទី ៥

### អវសានប្បញ្ញត្តិ

**មាត្រា ១៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៦ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្ត នូវព្រះរាជក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ។

**មាត្រា ១៧ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានប្បញ្ញត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០១*

លេខ: ១៨៧៦ .ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២១ ខែ ៨ ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៨០

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **ឈន អៀម** រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ ដោយធ្វើអោយវិស័យធម្មការ និង សាសនា មានការវិវត្តន៍រីកចំរើន ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ១៨៨ ច.ល

ដើម្បី[illegible]ក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០០១

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :....៨១....អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការកាត់ផ្ទៃដីក្រហមពីដែន
## ព្រៃសម្បទានសំរាប់ចំការកៅស៊ូ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីក្រហមចំនួន ៦.២០០ ហិកតា ចេញពីដែនព្រៃសម្បទានដែលក្នុងនោះផ្ទៃដីរបស់ក្រុមហ៊ុន ហ្គេត ចំនួន ២.១៨១ ហិកតា សហគ្រាសកូឡិចស៊ីមចំនួន ៣.៥៧៧ ហិកតា និងក្រុមហ៊ុន មៀង លី ហេង ចំនួន ៤៤២ ហិកតា ដែលស្ថិតនៅក្នុងឃុំទឹករីង ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានផែនទីបញ្ជាក់ទីតាំងជាឧបសម្ព័ន្ធជូនភ្ជាប់ ។

**មាត្រា ២** : ដីក្រហមនេះត្រូវប្រគល់អោយ :

- ប្រជាជនកំពង់កាន់កាប់ចំនួន ៩១២ ហិកតា
- ទុកបំរុងចែកជូនប្រជាជនសំរាប់ដាំកៅស៊ូជាលក្ខណ:គ្រួសារចំនួន ៩២៩ ហិកតា
- ចំការកៅស៊ូដុប សំរាប់ដាំកៅស៊ូជាលក្ខណៈឧស្សាហកម្មចំនួន ៤.៣៥៩ ហិកតា ។

**មាត្រា ៣** : ចំការកៅស៊ូជុប មានភារកិច្ចផ្តល់ជូនប្រជាជននូវសេវាបច្ចេកទេសក្នុងការដាំដុះ ការថែទាំរហូតដល់ការប្រមូលផល ។

**មាត្រា ៤** : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ត្រូវធ្វើការវាស់វែងដាក់ស្លាក និង រៀបចំធ្វើប្លង់កម្មសិទ្ធិកាន់កាប់ដីធ្លីជូនប្រជាជន និង ចំការកៅស៊ូជុប ។

**មាត្រា ៥** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន
## នៃគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៨០១ / ២៧៩ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍
- យោងតាមសំណើរបស់គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍

## ស ំ រេ ច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ :** អនុក្រឹត្យនេះកំណត់ពីបេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអគ្គលេខាធិការដ្ឋាន របស់គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ **"គ.ជ.ប.អ"** ។

## ជំពូកទី២

## បេសកកម្ម តួនាទី និង ភារកិច្ច

**មាត្រា២ :** គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយនាយកប្រតិបត្តិមួយរូប អមដោយនាយកប្រតិបត្តិរងពីររូប ។ នាយកប្រតិបត្តិមានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា៣ :** អគ្គលេខាធិការដ្ឋានរបស់ គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ មានបេសកកម្មអនុវត្តរាល់ការងាររបស់ **គ.ជ.ប.អ** ។ ក្នុងសកម្មភាពនេះអគ្គលេខាធិការដ្ឋានមានភារកិច្ចជាអាទិ៍ដូចខាងក្រោមនេះ ÷

- ធ្វើការសំរបសំរួលជាមួយក្រសួងពាក់ព័ន្ធនានា ភ្នាក់ងារ-អង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងបរទេសព្រមទាំងអង្គការមូលនិធិ និងអង្គការឯកជនពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ ។
- ធ្វើអោយដំណើរការ និងដាក់បញ្ហាប្រជាជនទៅក្នុងផែនការកម្មវិធីអភិវឌ្ឍន៍ របស់ក្រសួងពាក់ព័ន្ធក្នុងក្របខ័ណ្ឌជាតិអោយបានប្រសើរ និងមានប្រសិទ្ធភាព ។
- ធ្វើការសិក្សាអំពីដំណើរការអភិវឌ្ឍន៍ នៃការសំរេចចិត្តរបស់សន្និសីទអន្តរជាតិ ទាក់ទងនឹងបញ្ហាប្រជាជន និងការអភិវឌ្ឍន៍ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។
- រៀបចំចាត់ចែងការងារ ធ្វើកំណត់ហេតុ ធ្វើរបាយការណ៍ តាមដាននិងវាយតំលៃលើគំរោងកម្មវិធីប្រជាជន និងការអភិវឌ្ឍន៍របស់ក្រសួងពាក់ព័ន្ធ សំរាប់ផែនការជាតិ ។
- ទំនាក់ទំនងជាមួយរដ្ឋសភា ស្តីអំពីច្បាប់ដែលពាក់ព័ន្ធ នឹងប្រជាជននិងការអភិវឌ្ឍន៍ ។
- បណ្តុះបណ្តាលធនធានមនុស្សតាមរយៈសិក្ខាសាលា វគ្គបណ្តុះបណ្តាលនានា ដល់បុគ្គលិកមន្ត្រីរាជការទាំងថ្នាក់ជាតិ និងថ្នាក់ខេត្ត-ក្រុង និងរៀបចំអោយមានការស្រាវជ្រាវសមស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីអំពីការអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងរៀបចំយុទ្ធសាស្ត្រសន្តិសុខស្បៀង ។
- រៀបចំឯកសារនានាដែលពាក់ព័ន្ធ ហើយបោះពុម្ព ផលិត និងផ្សព្វផ្សាយតាមប្រព័ន្ធពត៌មាន ។
- រៀបចំ និងសំរបសំរួលសិក្ខាសាលា និងសន្និសីទ ស្តីអំពីប្រជាជន និងការអភិវឌ្ឍន៍ ។

**មាត្រា៤** : អគ្គលេខាធិការដ្ឋានរបស់ គ.ជ.ម.អ មានសិទ្ធិលើកសំណើ ពិនិត្យ និងសំរេចលើ សេចក្តីប្រកាសតែងតាំងការផ្ទេរភារកិច្ច ឬ ការបញ្ឈប់ពីតំណែងនូវមន្ត្រីថ្នាក់ក្រោម របស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ម.អ ។

## ជំពូកទី៣

## រចនាសម្ព័ន្ធ

**មាត្រា៥** : អគ្គលេខាធិការដ្ឋានរបស់ គ.ជ.ម.អ មានរចនាសម្ព័ន្ធដូចតទៅ ÷

១- ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច

២- ផ្នែកគំរោងការ និងកម្មវិធី

**មាត្រា៦** : ការបែងចែកភារកិច្ចរបស់បុគ្គលិក និងមន្ត្រីរាជការ ដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់ គ.ជ.ម.អ តាមសំណូមពររបស់នាយកប្រតិបត្តិ ។

**មាត្រា៧** : ផ្នែករដ្ឋបាល និងហិរញ្ញកិច្ច បំពេញការងាររបស់ខ្លួន គ្រប់គ្រងដោយនាយកប្រតិបត្តិរង និងអមដោយមន្ត្រីមួយចំនួនតាមការចាំបាច់ ដូចតទៅ ÷

- ទទួលខុសត្រូវផ្នែករដ្ឋបាល ចេញលិខិតស្នាម និងលិខិតអញ្ជើញ ។
- រៀបចំគំរោងថវិកា សំភារៈបរិក្ខា និងមធ្យោបាយការងារផ្សេងៗ ។
- គ្រប់គ្រងអចលនវត្ថុ ចលនវត្ថុ និងរាល់ការចំណាយផ្សេងៗ ។
- ធ្វើទំនាក់ទំនងលើបញ្ហាថវិកាជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គការនានា និងស្ថាប័នដែលពាក់ព័ន្ធ ។
- លើកគំរោងចំណាយថវិកា ក្នុងការបំពេញបេសកកម្មការងារ សិក្ខាសាលា សន្និសីទ កិច្ចប្រជុំផ្សេងៗ ។ល។

**មាត្រា៨** : ផ្នែកគំរោងការ និងកម្មវិធីបំពេញការងាររបស់ខ្លួន គ្រប់គ្រងដោយនាយកប្រតិបត្តិរង និងអមដោយមន្ត្រីមួយចំនួនតាមការចាំបាច់ ដូចតទៅ ÷

- គ្រប់គ្រង និងសំរបសំរួលរាល់ការងាររបស់អ្នកសំរបសំរួលកម្មវិធី ។
- រៀបចំគំរោង និងកម្មវិធីធ្វើការងារ ។
- ទំនាក់ទំនង សហការ និងសំរបសំរួលការងារជាមួយក្រសួង អង្គការនានា និងស្ថាប័នដែលពាក់ព័ន្ធ ។
- សរុបលទ្ធផល និងលើកយោបល់សុំការសំរេចពីរាជរដ្ឋាភិបាល ។

**មាត្រា៩ :** អគ្គលេខាធិការដ្ឋានរបស់ គ.ជ.ម.អ មានប្រើប្រាស់បុគ្គលិក និងមន្ត្រីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ដែលមានល័ក្ខខ័ណ្ឌការងារ និងប្រាក់បំណាច់ របស់បុគ្គលិកជាប់កិច្ចសន្យា ត្រូវកំណត់ដោយប្រកាសរបស់ គ.ជ.ម.អ តាមសំណើរបស់នាយកប្រតិបត្តិ ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា១០:** ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ម.អ ចាប់ពីថ្នាក់ការិយាល័យ ក្រុម និងផ្នែក ត្រូវកំណត់ដោយប្រកាសរបស់ គ.ជ.ម.អ តាមសំណើរបស់នាយកប្រតិបត្តិ ។

**មាត្រា១១ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា១២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋាន
## នៃគណៈកម្មាធិការជាតិដើម្បីប្រជាជន និងការអភិវឌ្ឍន៍



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣ [illegible] អនក្រ.ចត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ក្រសួងអប់រំយុវជន និងកីឡា

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់មេដាយ មុនីសារាភ័ណ្ឌ ជូនយុវសិស្សពូកែថ្នាក់ទី ៩ និងថ្នាក់ទី ១២ ចំនួន ៥៣ នាក់ នៅទូទាំងប្រទេសសំរាប់ឆ្នាំសិក្សា ២០០០ - ២០០១ លើមុខវិជ្ជា ផ្នែកអក្សរសាស្ត្រខ្មែរ- ផ្នែកគណិតវិទ្យា ផ្នែករូបវិទ្យា ដូចមានខាងក្រោម ÷

**ក**- មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្នែកអក្សរសាស្ត្រខ្មែរ ថ្នាក់ទី ៩ និងថ្នាក់ទី ១២

១- សិស្ស ម៉េង ភ័ណ្ឌដារី ភេទ ស្រី
២- សិស្ស សារ៉ាយ ភូមិរ៉ា ភេទ ស្រី
៣- សិស្ស ជ័យ ចាន់ពុទ្ធានី ភេទ ស្រី
៤- សិស្ស សេង វ៉ាន់ម៉ារ៉េន ភេទ ប្រុស

**ខ**- មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្នែកគណិតវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២

១- សិស្ស ដួង ចំរើន ភេទ ប្រុស
២- សិស្ស វង្ស ច័ន្ទភក្តិ ភេទ ប្រុស
៣- សិស្ស ឡេង វ៉ាន់ឌី ភេទ ប្រុស
៤- សិស្ស ជា វឌ្ឍនៈ ភេទ ប្រុស

**គ**- មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ផ្នែករូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២

១- សិស្ស ប៉ា វុត្ថា ភេទ ប្រុស
២- សិស្ស ជួន វុត្ថា ភេទ ប្រុស
៣- សិស្ស ទី សុវណ្ណរដ្ឋ ភេទ ស្រី
៤- សិស្ស សុខ ហួត ភេទ ប្រុស

**ឃ**- មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ផ្នែកអក្សរសាស្ត្រខ្មែរ ថ្នាក់ទី ៩ និងថ្នាក់ទី ១២

១- សិស្ស យក់ លក្ខិណាន ភេទ ស្រី
២- សិស្ស ទូច ដារិទ្ធរង្សី ភេទ ស្រី
៣- សិស្ស នង បញ្ញាសុវត្ថិ ភេទ ស្រី
៤- សិស្ស អ៊ុង សុមាលា ភេទ ស្រី

៣- សិស្ស កុយ សិរីរតនៈ ភេទ ប្រុស ៦- សិស្ស ស្រ៊ុន ឈន់វលក្ខណ៍ ភេទ ស្រី

**ខ- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ សេនា ផ្នែកគណិតវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២**

១- សិស្ស ឈួយ ឈុំ ភេទ ប្រុស ៤- សិស្ស ហេង សាលពិសុទ្ធ ភេទ ប្រុស

២- សិស្ស ជៀប សុវុទ្ធី ភេទ ប្រុស ៥- សិស្ស អៀច សេដ្ឋា ភេទ ប្រុស

៣- សិស្ស វិន វឌ្ឍនី ភេទ ស្រី ៦- សិស្ស ហេង ដារ៉ាវុធ ភេទ ប្រុស

**ច- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ សេនា ផ្នែករូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២**

១- សិស្ស អ៊ា សុជាតិ ភេទ ប្រុស ៤- សិស្ស ជា សំកុល ភេទ ប្រុស

២- សិស្ស សុត រតនា ភេទ ប្រុស ៥- សិស្ស ជា រស្មី ភេទ ប្រុស

៣- សិស្ស សួន វណ្ណៈ ភេទ ប្រុស ៦- សិស្ស ជួន វិបុល ភេទ ប្រុស

**ឆ- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ផ្នែកអក្សរសាស្ត្រខ្មែរ ថ្នាក់ទី ៩ និងថ្នាក់ទី ១២**

១- សិស្ស ជុំប មុលី ភេទ ស្រី ៥- សិស្ស ហាក់ សុខហេង ភេទ ប្រុស

២- សិស្ស យូ រ៉ាយុត្តិ ភេទ ប្រុស ៦- សិស្ស ហ៊ីង សុភាព ភេទ ស្រី

៣- សិស្ស មិន សីហា ភេទ ប្រុស ៧- សិស្ស ស៊ូ បុប្ផា ភេទ ស្រី

៤- សិស្ស ពៅ ប៊ុនខ្សៀន ភេទ ប្រុស

**ជ- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ផ្នែកគណិតវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២**

១- សិស្ស ភាន់ ប៊ុនរតនា ភេទ ប្រុស ៤- សិស្ស ចាយ ពណ្ណរាយ ភេទ ប្រុស

២- សិស្ស អៀង ផាន់ណា ភេទ ប្រុស ៥- សិស្ស តាំង វ៉ាសនា ភេទ ប្រុស

៣- សិស្ស កាំង សោមាវត្តី ភេទ ស្រី ៦- សិស្ស ម៉ឹង លក្ខិណា ភេទ ស្រី

**ឈ- មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ផ្នែករូបវិទ្យា ថ្នាក់ទី ៩ និងថ្នាក់ទី ១២**

១- សិស្ស ទូត វុទ្ធី ភេទ ប្រុស ៦- សិស្ស លី គិមឡុង ភេទ ប្រុស

២- សិស្ស ហេង ដារ៉ា ភេទ ប្រុស ៧- សិស្ស ប៊ុច ឧសភា ភេទ ប្រុស

៣- សិស្ស ផៃ សុភា ភេទ ប្រុស ៨- សិស្ស ដៅ ប៉េងស៊ុន ភេទ ប្រុស

៤- សិស្ស ហ៊ុន សុភារី ភេទ ស្រី ៩- សិស្ស ហ៊ួត ចាន់ធី ភេទ ប្រុស

៥- សិស្ស ឃិត វុទ្ធី ភេទ ប្រុស ១០- សិស្ស តាំងអាំង សេរីវុធ ភេទ ប្រុស

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៧៣ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការតែងតាំងអភិបាលរងខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **មួន ម៉ីយ** ជាអភិបាលរងទី២ ខេត្តរតនគិរី ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧៤ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានលុបឈ្មោះលោក **ប៊ុនហួម អ៊ួនម៉ានី** ចេញពីក្របខ័ណ្ឌរដ្ឋបាលស៊ីវិល នៃក្រសួងមហាផ្ទៃ ដោយមូលហេតុ ទទួលមរណភាព ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៧ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងអភិបាលរងខេត្ត ក្រុង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** តែងតាំងអស់លោក ជាអភិបាលរងខេត្ត ក្រុង ដែលមានរាយនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | លោក | ខ័ន ឈុនលី | ជាអភិបាលរងទី១ ខេត្តក្រចេះ |
| ២- | លោក | ឆោម ប៊ុនខន | ជាអភិបាលរងទី១ ខេត្តរតនគិរី |
| ៣- | លោក | ផ្លូន គីមឆុន | ជាអភិបាលរងទី១ ខេត្តកោះកុង |
| ៤- | លោក | ប្រាក់ ស៊ីហារ៉ា | ជាអភិបាលរងទី២ ក្រុងព្រះសីហនុ |
| ៥- | លោក | ម៉ី សាម៉ន | ជាអភិបាលរងទី២ ខេត្តឧត្តរមានជ័យ |

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣ "ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៧៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការផ្លាស់ប្តូរ និងផ្ទេរភារកិច្ចអភិបាលរងខេត្ត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ :** ត្រូវបានផ្លាស់ប្តូរ និងផ្ទេរភារកិច្ចលោក ម៉ឿង វិគល អភិបាលរងទី២ ខេត្តឧត្តរមានជ័យ អោយមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៧៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

### សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនចំនួន ០២រូបដែលបានធ្វើវិភាគទាន ជូនដល់សភាពាណិជ្ជកម្មរាជធានីភ្នំពេញ សំរាប់រៀបចំពិធីសម្ពោធ អាគារទីស្នាក់ការអចិន្ត្រៃយ៍សភាពាណិជ្ជកម្ម ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **តាំង ឃាក់ស៊្រុន** ថវិកាចំនួន ១៥.០០០ ដុល្លារអាមេរិក

២-លោកជំទាវ **កែវ ម៉ាលី** ថវិកាចំនួន ១០.០០០ ដុល្លារអាមេរិក

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៧៨ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស / រកត / ០៣៩៩ / ៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល

## សំរេច

**មាត្រា ១.-**

ត្រូវបានតែងតាំងអស់លោក លោកស្រី ដូចមានរាយនាមខាងក្រោម :

១- លោក **ហង្ស អាំអាន** ជាប្រធានក្រុមតំរោងតារាងបៀវត្ស មានឋានៈស្មើអគ្គនាយករង

២- លោក **ឈួន អាម** ជាប្រធានក្រុមតំរោងកន្សោមអាទិភាព មានឋានៈស្មើអគ្គនាយករង

៣- លោក **ឌឹង សុខៃ** ជាប្រធានក្រុមតំរោងជំរឿនមន្ត្រីរាជការ មានឋានៈស្មើអគ្គនាយករង

៤- លោក **សួង លាងហៃ** ជាប្រធានក្រុមតំរោងនីតិកម្ម មានឋានៈស្មើអគ្គនាយករង

៥- លោក **ឈីម ផាទីន** ជាប្រធានក្រុមតំរោងវិភាគមុខងារ មានឋានៈស្មើអគ្គនាយករង

៦- លោក **គង់ សុភី** ជាប្រធានក្រុមកិច្ចការអភិបាលកិច្ច មានឋានៈស្មើប្រធាននាយកដ្ឋាន

៧- លោក **អ៊ុក សំបូរ** ជាប្រធានក្រុមតំរោងគោលនយោបាយ ក្របខ័ណ្ឌ និង អធិការកិច្ច មានឋានៈស្មើប្រធាននាយកដ្ឋាន

៨- លោក **យិន ឈយន** ជាប្រធានក្រុមកិច្ចការរដ្ឋបាលទូទៅ មានឋានៈស្មើប្រធាននាយកដ្ឋាន

៩- លោក **ប្រាក់ ទីត្រា** ជាប្រធានក្រុមកិច្ចការផ្គត់ផ្គង់ មានឋានៈស្មើប្រធាននាយកដ្ឋាន

១០- លោក **ហុក ម៉េងសេ** ជាប្រធានក្រុមតំរោង វិសហមជ្ឈការ វិមជ្ឈការ និង សេវាសាធារណៈ មានឋានៈស្មើប្រធាននាយកដ្ឋាន

១១- លោក **ស ចាន់ធី** ជាប្រធានក្រុមតំរោងកម្មវិធីបណ្តុះបណ្តាល មានឋានៈស្មើប្រធាននាយកដ្ឋាន

១២- អ្នកស្រី **គង់ កែវសារី** ជាប្រធានក្រុមកិច្ចការប្រព័ន្ធពត៌មានវិទ្យា មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចមាត្រា ៣*

*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**លេខៈ ៣៧៩ អនក្រ.តត**

**អនុក្រឹត្យ**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

**ស ំ រេ ច**

**មាត្រា ១ :** តែងតាំងលោក **អន ម៉ុណ្ណារ៉ែន** ជាប្រធាននាយកដ្ឋានមណ្ឌលបណ្តុះបណ្តាល និងវិក្រឹត្យការវិជ្ជាជីវៈសារពត៌មាន នៃក្រសួងពត៌មាន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែសីហាឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៨០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សម្តេចប្រធានព្រឹទ្ធសភា

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់**មេដាយ មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការសាងសង់ នៃព្រឹទ្ធសភា ចំនួន ០៧រូប ដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ក្នុងការទាក់ទាញរកជំនួយពីបរទេស ដើម្បីជួយកសាងអាគារនានាក្នុងស្ថាប័នព្រឹទ្ធសភាសរុបទឹកប្រាក់ជិត ៤លានដុល្លារអាមេរិក និងបានសហការអស់ពីកំលាំងកាយចិត្តជាមួយភាគីមិត្តចិន ក្នុងការសាងសង់ និងជួសជុលអាគារទាំងឡាយ ក្នុងមន្ទីរព្រឹទ្ធសភាបានចប់ជាស្ថាពរដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមុនីសារាភ័ណ្ឌថ្នាក់ធិបឌិន្ទ :**

-ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា

**ខ_មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនា :**

១-ឯកឧត្តម **ជា សុន** នាយកខុទ្ទកាល័យសម្តេច ជា ស៊ីម

២-ឯកឧត្តម **ញឹក ឆៃអេង** អគ្គលេខាធិការរងព្រឹទ្ធសភា

៣-ឯកឧត្តម **មាន សុខុម** អគ្គាធិការ

៤-លោក **រ័ត្ន សៀមគីមសេង** អគ្គាធិការ

៥-លោក **ឈឹម ព្រះខ័ន** អគ្គាធិការ

៦-លោក **ឡុង ធុន្ន** អគ្គាធិការ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៨១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សម្តេចប្រធានព្រឹទ្ធសភា

## សំរេច

**មាត្រា១** : ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនសមាជិកគណៈកម្មការសាងសង់នៃព្រឹទ្ធសភាចំនួន ០៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនព្រឹទ្ធសភាលើការងារសាងសង់ និងជួសជុលអគារទាំងឡាយក្នុងស្ថាប័នព្រឹទ្ធសភា ដូចមានរាយនាមខាងក្រោមនេះ ÷

**ក_មេដាយមាសការងារ :**

| | | |
|---|---|---|
| ១-លោក | **ឡេក ឆាយ** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ |
| ២-លោក | **គីម លី** | ប្រធាននាយកដ្ឋាននីតិវិធី |
| ៣-លោក | **គីម សុគន្ធ** | ប្រធាននាយកដ្ឋានរដ្ឋបាល |

**ខ-មេដាយប្រាក់ការងារ :**

១-លោក **គីម សុផា** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

២-លោក **ញៀម រ៉េន** អនុប្រធាននាយកដ្ឋានរដ្ឋបាល

**គ-មេដាយសំរឹទ្ធការងារ :**

១-លោក **ហ៊ឹម ឌុន** ប្រធានការិយាល័យពិធីការ

២-លោក **ទេព ចាន់អុនឧត្តរក្ស** ប្រធានការិយាល័យបច្ចេកទេស

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និងមាត្រា២

-រាជកិច្ច

-កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧២ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

### សំរេច

**ប្រការ១:** ត្រូវបានប្រគល់ មេដាយមាសការងារ ជូននាយទាហាន នាយនគរបាល សិល្បៈករ សិល្បៈការិនី និងកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន ចំនួន ២៥ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ជូនជាតិមាតុភូមិ ដូចមានរាយនាមជូនខាងក្រោម ÷

| | | | |
|---|---|---|---|
| ១-លោកវរសេនីយ៍ឯក | **ទិសុទ្ធ** | **សំបូរ** | នាយរងសេនាធិការ |
| ២-លោកវរសេនីយ៍ឯក | **អន** | **សារិទ្ធ** | នាយរងសេនាធិការ |
| ៣-លោកវរសេនីយ៍ឯក | **ឌួន** | **សំអាន** | នាយរងសេនាធិការបញ្ជាការដ្ឋាន |
| ៤-លោកវរសេនីយ៍ឯក | **ប៉ែន** | **រ៉ា** | នាយរងសេនាធិការបញ្ជាការដ្ឋាន |
| ៥-លោកវរសេនីយ៍ឯក | **ឌួន** | **សុវណ្ណា** | អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន |
| ៦-លោកវរសេនីយ៍ត្រី | **យ៉ិន** | **គា** | អនុប្រធានការិយាល័យនាយកដ្ឋានរដ្ឋបាល |

| | | | |
|---|---|---|---|
| ៧-លោកវរសេនីយ៍ទោ | ចុង | ម៉ន | នាយរងការិយាល័យទី ៥ |
| ៨-លោកវរសេនីយ៍ទោ | ជួង | ជី | សិល្បៈករ |
| ៩-លោកវរសេនីយ៍ទោ | អ៊ូ | ប៊ុណ្ណារ៉ាត់ | សិល្បៈករ |
| ១០-លោកវរសេនីយ៍ទោ | ធូ | ចាំរ៉ុង | សិល្បៈករ |
| ១១-លោកវរសេនីយ៍ត្រី | ជា | លីស្រ៊ុន | សិល្បៈករ |
| ១២-លោកវរសេនីយ៍ត្រី | មាស | ស៊ីថុន | សិល្បៈករ |
| ១៣-លោកវរសេនីយ៍ត្រី | សំ | សារុន | សិល្បៈករ |
| ១៤-លោកវរសេនីយ៍ត្រី | អៀម | ច័ន្ទថា | សិល្បៈករ |
| ១៥-លោកអនុសេនីយ៍ឯក | ម៉ៅ | សាមឿន | សិល្បៈករ |
| ១៦-លោកអនុសេនីយ៍ឯក | ផាត | សុផារ៉ា | សិល្បៈករ |
| ១៧-លោកអនុសេនីយ៍ឯក | ម៉ែ | សារិទ្ធ | សិល្បៈករ |
| ១៨-លោកអនុសេនីយ៍ឯក | ម៉ូ | សាខន | សិល្បៈករ |
| ១៩-លោកអនុសេនីយ៍ឯក | ម៉ម | សារ៉ាត់ | សិល្បៈករ |
| ២០-លោកអនុសេនីយ៍ឯក | ហ៊ុន | សាវ៉ាត | សិល្បៈករ |
| ២១-លោកអនុសេនីយ៍ឯក | យ៉ាន់ | ម៉េងហួន | សិល្បៈករ |
| ២២-អ្នកស្រី | ប៉ក់ | សំអុល | សិល្បៈការិនី |
| ២៣-អ្នកស្រី | សុខ | ជឿន | សិល្បៈការិនី |
| ២៤-អ្នកស្រី | សួន | សំអឿន | សិល្បៈការិនី |
| ២៥-អ្នកស្រី | ម៉ៅ | ស៊ីណារាត | សិល្បៈការិនី |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ ៧ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

